# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា

ការិយាល័យផ្នែក សិទ្ធិ និង ការទទួលខុសត្រូវ របស់សិស្ស
**440 N. Broad Street,** ជាន់ទី២
**PHILADELPHIA, PA 19130**
**Rachel Holzman, Esq.,** នាយិការង
ទូរស័ព្ទ៖ ២១៥-៤០០-៤៨៣០ / ទូរសារ៖ ២១៥-៤០០-៤៨៣១

## ការណែនាំសម្រាប់មាតាបិតា អំពីវិធីដាក់វិន័យសិស្ស

I. អ្វីៗដែលត្រូវដឹងនៅពេលដែលកូនលោកអ្នកជាប់ទាក់ទិននឹងឧប្បត្តិហេតុអ្វីមួយ ដែលនៅក្នុងក្រមសីលធម៌នៃអាកប្បកិរិយាសិស្សរបស់ក្រសួង តម្រូវឲ្យមានសវនាការដាក់វិន័យសិស្ស។

ក. សាលាត្រូវផ្ដល់ដំណឹងអំពីឧប្បត្តិហេតុដែលកូនលោកអ្នកជាប់ទាក់ទិន។

ខ. ទទួលលិខិតបញ្ឈប់បណ្ដោះអាសន្ន ដែលមានព័ត៌មានលម្អិតអំពីអាកប្បកិរិយាដែលនាំឲ្យរំខាន ចំនួនថ្ងៃដែលត្រូវបញ្ឈប់បណ្ដោះអាសន្ន និង ថ្ងៃខែ និង ពេលវេលាដែលឲ្យសិស្សត្រឡប់មករៀនវិញ/ជួបប្រជុំជាមួយមាតាបិតា។

គ. ចូលរួមក្នុងអង្គប្រជុំជាមួយមាតាបិតា ដែលនឹងមាននូវអ្វីៗកើតឡើង ដូចតទៅ៖

១. គេនឹងជម្រាបលោកអ្នកយ៉ាងលម្អិតនូវអ្វីៗដែលទាក់ទងនឹងឧប្បត្តិហេតុ ការជាប់ទាក់ទិនរបស់កូនលោកអ្នក មូលហេតុដែលសាលាស្នើសុំឲ្យមានសវនាការដាក់វិន័យសិស្ស និងអ្វីៗដែលត្រូវធ្វើតាមវិធីនេះទៅថ្ងៃមុខ។

២. គេនឹងអនុញ្ញាតឲ្យលោកអ្នកពិនិត្យមើលភស្ដុតាងទាំងអស់ ដែលជាប់ទាក់ទិននឹងកូនលោកអ្នកនៅក្នុងឧប្បត្តិហេតុនេះ។ ភស្ដុតាងអាចមានជា រូបថត វីដេអូ សេចក្ដីរាយការណ៍ របាយការណ៍។ល។ គេនឹងយកព័ត៌មានដែលទាក់ទងនឹងសិស្សផ្សេងទៀតចេញពីភស្ដុតាងទាំងនេះ។

៣. គេនឹងផ្ដល់ជូនលោកអ្នកនូវឯកសារដែលបានកត់ត្រាទុក**ទាំងអស់** (សំណុំឯកសារ EH-21 ទាំងអស់) ដែលគេបានបញ្ជូនទៅ ការិយាល័យផ្នែក សិទ្ធិ និង ការទទួលខុសត្រូវ របស់សិស្ស ជាមួយនឹង សំណើសុំឲ្យមានសវនាការដាក់វិន័យសិស្ស របស់សាលា។ ឯកសារនេះនឹងមិនមានឯកសារពេទ្យដែលទាក់ទងនឹងអ្នកដទៃទៀតនោះទេ។

៤. គេនឹងផ្ដល់ដំណឹងដល់លោកអ្នកអំពីសំណូមពរនៃការដាក់វិន័យរបស់សាលា។ សាលាអាចសុំឲ្យគេទុកកូនលោកអ្នកឲ្យនៅសាលានេះដដែល ដោយមានកិច្ចព្រមព្រៀងផ្នែកអាកប្បកិរិយា ឬ សុំឲ្យកូនរបស់លោកអ្នកផ្លាស់ទៅសាលារដ្ឋផ្សេងទៀត ឬ ផ្លាស់ទៅសាលាដែលមានវិន័យតឹងរឹង។

៥. គេនឹងផ្ដល់ជូនលោកអ្នកនូវ កម្មវិធីផ្ដល់ជំនួយដល់សិស្ស (SAP)។ ការធ្វើដូច្នេះអាចផ្ដល់ឲ្យកូនលោកអ្នកនូវ ការវាយតម្លៃផ្នែកអាកប្បកិរិយា និង ជំនួយព្យាបាល។ **ការយល់ព្រមទទួលយកការបម្រើនេះ មិនមែនមានន័យថាកូនរបស់លោកអ្នកទទួលកំហុសនោះទេ។**

ឃ. ការត្រឡប់មករៀនវិញនៅពេលផុតកំណត់ថ្ងៃបញ្ឈប់បណ្ដោះអាសន្ន ដែលបានបញ្ជាក់នៅលើលិខិតបញ្ឈប់បណ្ដោះអាសន្ន។ ការបញ្ឈប់បណ្ដោះអាសន្នមិនអាចលើសពី១០ថ្ងៃជាប់ៗគ្នាបានទេ។

កំណត់សម្គាល់៖ បើសិនជាកូនលោកអ្នកជាប់ពាក់ព័ន្ធនឹងឧប្បត្តិហេតុអ្វីមួយ ដែលគេដឹងថាមានជនរងគ្រោះ គេអាចផ្លាស់ប្ដូរ ថ្នាក់ និង/ឬ កាលវិភាគសិក្សា របស់កូនលោកអ្នក ដើម្បីបំបែកកូនលោកអ្នកពីជនរងគ្រោះនោះ។

II. ក្រោយពី ការិយាល័យផ្នែក សិទ្ធិ និង ការទទួលខុសត្រូវ របស់សិស្ស បានទទួលសំណើឲ្យមានសវនាការ ហើយបានកំណត់ពេលសម្រាប់ សវនាការដាក់វិន័យសិស្ស រួចហើយ នឹងមានអ្វីៗកើតឡើង ដូចតទៅះ

ក. លោកអ្នកនឹងទទួល លិខិតកោះហៅឲ្យឡើងសវនាការ ដែលបានបញ្ជាក់ពី ថ្ងៃខែ ម៉ោង និង ទីកន្លែង។

១. បើសិនជាលោកអ្នក និង/ឬ កូនរបស់លោកអ្នក មិនអាចមកចូលរួមក្នុងសវនាការដែលបានកំណត់ពេលរួចហើយនោះទេ លោកអ្នកត្រូវជម្រាបដល់ ការិយាល័យផ្នែក សិទ្ធិ និង ការទទួលខុសត្រូវ របស់សិស្ស ជាបន្ទាន់ តាមរយៈទូរស័ព្ទលេខ ២១៥-៤០០-៤៨៣០។

ខ. គេអនុញ្ញាតឲ្យលោកអ្នក និងកូនរបស់លោកអ្នក មានអ្វីៗដូចតទៅ នៅក្នុងសវនាការះ

១. នាំសាក្សីផ្ទាល់របស់លោកអ្នក។

២. បង្ហាញ ភស្តុតាង និង របាយការណ៍។

៣. នាំ ក្រុមគ្រួសារ អ្នកតំណាង អ្នកគាំទ្រ មេធាវី ។ល។

គ. ភ្នាក់ងារខាងសវនាការនឹងសួរ លោកអ្នក កូនរបស់លោកអ្នក អ្នកដែលលោកអ្នកនាំមកជាមួយ ព្រមទាំងអ្នកតំណាងឲ្យសាលា នូវសំណួរដែលទាក់ទងនឹង ឧប្បត្តិហេតុ និង កូនរបស់លោកអ្នក។

ឃ. ភ្នាក់ងារខាងសវនាការនឹងសម្រេច ថាតើកូនរស់លោកអ្នកបានប្រព្រឹត្តបទល្មើសដែលគេកំពុងស្វែងយល់ និងការដាក់វិន័យដែលសមរម្យទៅតាមនោះ។

ង. ការសរសេរដោយសង្ខេបអំពីសវនាការ ដែលរួមមាន ការសម្រេចរបស់ភ្នាក់ងារខាងសវនាការ នឹងផ្តល់ជូនលោកអ្នក នៅពេលចប់សវនាការ ឬក្នុងរយៈពេល៤៨ម៉ោង ក្រោយសវនាការ។